ចិត្តលើព្រះយេស៊ូវ នឹងមានជីវិតអស់កល្បជានិច្ច ប៉ុន្តែមនុស្សទាំងអស់ដែលមិនដែលទុកចិត្តលើព្រះយេស៊ូវ នោះគ្មានជីវិតអស់កល្បជានិច្ចឡើយ ។ យ៉ូហានទី១ ៥:១២ និយាយថា” ឯអ្នកណាដែលមានព្រះរាជបុត្រា នោះក៏មានជីវិតដែរ តែអ្នកណាដែលគ្មានព្រះរាជបុត្រានៃព្រះទេ នោះគ្មានជីវិតឡើយ ”។

* យើងទាំងអស់គ្នាមានជីវិតតែមួយ (គ្មានជីវិតច្រើនទេ) គឺមានជីវិតតែមួយ ។
* មានព្រះពិតតែមួយ (គ្មានព្រះច្រើនទេ) គឺមានព្រះពិតតែមួយ ។
* មានផ្លូវតែមួយសំរាប់ទៅថានសួគ៌ (គ្មានផ្លូវច្រើនទេ) គឺមានផ្លូវតែមួយ

# មានតែមួយ



ការិយាល័យ សំរាប់ទាក់ទង
ប្រអប់ ប្រៃសណីយ៍ ២៥០៦
ភ្នំពេញ ៣

## ជីវិតតែមួយ

សាសនាខ្លះបង្រៀនថា ពេលមនុស្សស្លាប់ គេនឹងចាប់កំណើតដូចជាអ្វីផ្សេង ។ ប្រសិនបើគេបានធ្វើការល្អក្នុងជីវិតគេ ប្រហែលជាជីវិតពេលក្រោយល្អជាងជីវិតមុន ប៉ុន្តែបើគេបានធ្វើបាបច្រើនគេនិងចាប់កំណើតដូចជាអ្វីដែលអាក្រក់ ប្រហែលជាសត្វឆ្កែ ឬសត្វពស់ ឬ មនុស្សក្រ ។ តើនេះពិត ឬមិនពិត ? ព្រះបន្ទូលរបស់ព្រះប្រាប់យើងថា មនុស្សទាំងអស់មានជីវិតតែមួយ ។ ព្រះគម្ពីរថា" ហើយដោយព្រោះដំរូវត្រូវឱ្យមនុស្សទាំងអស់ស្លាប់មួយដង រួចសឹមជាប់សេចក្តីជំនុំជំរះ" ។ ព្រះគម្ពីរប្រាប់យើងថាក្រោយយើងស្លាប់ យើងមិនចូលលោកីយម្តងទៀតឡើយ ដូចជាមនុស្សដទៃ ឬសត្វផ្សេងៗទេ ប៉ុន្តែយើងត្រូវឈរខាងមុខទីជំនុំជំរះរបស់ព្រះ យើងទាំងអស់មានជីវិតតែមួយ ។

## ព្រះពិតតែមួយ

មនុស្សជាច្រើនគិតថាមានព្រះច្រើន ប៉ុន្តែព្រះបន្ទូលរបស់ព្រះថានេះមិនត្រូវទេ អារក្សសាតាំងដែលជាសត្រូវរបស់ព្រះ ចង់ឱ្យមនុស្សទាំងអស់ច្រឡំអំពីព្រះជាអ្នកណា ពីព្រោះអារក្សសាតាំងស្អប់ព្រះណាស់ ព្រះគម្ពីរថាមានព្រះពិតតែមួយ។

អេសាយ ៤៤:៦ ប្រាប់យើងថា" ទ្រង់មានបន្ទូលថា អញជាដើម ជាចុង ក្រៅពីអញគ្មានព្រះណាទៀតឡើយ" ក្នុង ៦៨ ព្រះសួរសំនួរនេះថា " តើមានព្រះណាក្រៅពីអញឬទេ អើ គ្មានថ្មដាណាទៀតឡើយ អញមិនស្គាល់ណាមួយសោះ"។ មនុស្សច្រើនបង្កើតព្រះខ្លះ ដោយដៃរបស់ខ្លួន ប៉ុន្តែព្រះគម្ពីរសួរយើងថា តើព្រះដែលយើងបង្កើតខ្លួនឯងមានអំណាចដូចម្តេច? នៅ អេសាយ ៤៤ ព្រះគម្ពីរនិយាយអំពីព្រះផ្សេងៗ ដែលមនុស្សបង្កើតដោយដៃរបស់គេថា" ពួកអ្នកដែលឆ្លាក់ធ្វើរូបព្រះ គេសុទ្ធតែអសារឥតការទាំងអស់.......តើអ្នកណានឹងសូន្យធ្វើព្រះ ឬសិតធ្វើរូបដែលឥតមានប្រយោជន៍ដូច្នេះ.....អើក៏ធ្វើព្រះមួយឡើង រួចក្រាបថ្វាយបង្គំគឺគាត់ឆ្លាក់ធ្វើជារូប ហើយក្រាបចុះគោរពដល់រូបនោះ...... ក៏ក្រាបចុះថ្វាយបង្គំ ហើយអធិស្ឋានដល់រូបនោះដោយពាក្យថា សូមជួយសង្គ្រោះខ្ញុំផង ពីព្រោះលោកជាព្រះនៃខ្ញុំ......ពួកនោះមិនដឹងទេក៏មិនយល់សោះ ដ្បិតភ្នែកគេត្រូវបាំងមិនឱ្យមើលឃើញ ហើយចិត្តគេផង ដើម្បីមិនឱ្យយល់បាន" ព្រះបន្ទូលរបស់ព្រះថា យើងគួរគិតអំពីនេះ នឹងកុំថ្វាយបង្គំព្រះដែលមិនពិត ។ មានព្រះពិតតែមួយប៉ុណ្ណោះ ហើយនឹងឈ្មោះរបស់ព្រះនោះគឺ ព្រះយេស៊ូវ ។ យ៉ូហាន ១៧:៣ ព្រះគម្ពីរនិយាយថា" នេះជាជីវិតដ៏នៅអស់កល្បជានិច្ច គឺឱ្យគេបានស្គាល់ដល់ទ្រង់ ដ៏ជាព្រះពិតតែមួយ នឹងព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានចាត់ឱ្យមកផង"

## ផ្លូវតែមួយសំរាប់ទៅឋានសួគ៌

មនុស្សច្រើនគិតថាផ្លូវទាំងអស់ទៅឋានសួគ៌ហើយគេគិតថា បើគេធ្វើការល្អក្នុងជីវិតគេ អត់អីទេ នោះបើសិនជាជឿលើ មហាមេត ឬ ព្រះពុទ្ធ ឬ ព្រះយេស៊ូវ ប៉ុន្តែព្រះគម្ពីរថាម៉េច? ព្រះគម្ពីរថាមានផ្លូវតែមួយដែលទៅឋានសួគ៌ ហើយផ្លូវនោះគឺជាព្រះយេស៊ូវគ្រីស្ទ ។ នៅយ៉ូហាន ១៤:៦ ព្រះគម្ពីរថា" ព្រះយេស៊ូវមានបន្ទូលទៅគាត់ថា ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំនោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ" យើងទាំងអស់មានជីវិតតែមួយ ហើយក្រោយយើងស្លាប់ យើងត្រូវឈរខាងមុខនៅចំពោះព្រះពិតតែមួយ ឈ្មោះព្រះយេស៊ូវ ។ មនុស្សទាំងអស់ដែលបានទុក